ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

# ឱកាសការងារ

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណផ្លូវការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មពី **ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** ដោយសម្រេចបាននូវភាពជោគជ័យ និងការរីកចម្រើនយ៉ាងឆាប់រហ័ស។ ជាក់ស្តែង **ហ្វូតាបា** បានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនជាបន្តបន្ទាប់ ដោយបានដាក់ឱ្យដំណើរការ ការិយាល័យសាខាចំនួនបួន (៤) ក្នុងនោះរួមមាន៖ ពីរ (២) សាខា ស្ថិតក្នុងរាជធានីភ្នំពេញ មួយ (១) សាខាស្ថិតក្នុងខេត្តកំពង់ស្ពឺ និងមួយ (១) សាខាទៀត ស្ថិតក្នុងខេត្តតាកែវ ដែលជាសាខាថ្មីទើបដាក់ឱ្យដំណើរការបន្ថែមក្នុងខែមីនា ឆ្នាំ២០២៣នេះផងដែរ។ បច្ចុប្បន្ន **ហ្វូតាបា** ត្រូវការជ្រើសរើសបុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើការងារក្នុងមុខតំណែងដូចខាងក្រោម៖

| មុខតំណែង | ចំនួនជ្រើសរើស | សាខា | ទីតាំងការងារ |
|---|---|---|---|
| មន្ត្រីសវនករផ្ទៃក្នុង | ០១ នាក់ | ការិយាល័យកណ្តាល | រាជធានីភ្នំពេញ |

## ភារកិច្ច និងការទទួលខុសត្រូវ

- ផ្តោតលើការអនុវត្តកម្មវិធី ផែនការ និងប្រព័ន្ធនៃការធ្វើសវនកម្មផ្ទៃក្នុង។
- ត្រួតពិនិត្យលើគុណភាពនៃរបាយការណ៍ និងការអនុវត្តការងារសវនកម្មផ្ទៃក្នុង។
- រៀបចំរបាយការណ៍ និងឯកសារស្នើសុំដោយអ្នកត្រួតពិនិត្យ និងមានការស្នើសុំជាចាំបាច់ដោយអ្នកគ្រប់គ្រង។
- ធ្វើសវនកម្មពិសេស ឬការស៊ើបអង្កេត។
- ធ្វើការប្រមូល និងវិភាគទិន្នន័យក្នុងការធ្វើសវនកម្ម។
- រៀបចំឯកសារសវនកម្មផ្ទៃក្នុង និងរបាយការណ៍នៃការរកឃើញតាមសាខា។
- ត្រួតពិនិត្យលើការគ្រប់គ្រងឯកសារ និងទ្រព្យដាក់ធានាក្នុងសាខា។
- ចុះត្រួតពិនិត្យអតិថិជន តាមសហគមន៍នៅក្នុងកម្រិតសាខា។
- ជួយបង្កើត អភិវឌ្ឍ ឬកែប្រែនីតិវិធី គោលនយោបាយ កម្មវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង។
- ត្រួតពិនិត្យការទទួលខុសត្រូវផ្ទាល់ខ្លួន នៃការចុះបេសកកម្ម ដើម្បីប្រាកដថា កិច្ចការដែលបានចាត់តាំងបានបំពេញ រួចរាល់ទៅតាមពេលវេលាកំណត់។
- ទំនាក់ទំនងល្អជាមួយប្រធានគ្រប់គ្រងផ្ទាល់ និងក្រុមការងារ ដើម្បីកំណត់ហានិភ័យ។

## លក្ខខណ្ឌជ្រើសរើស

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬអនុបណ្ឌិតជំនាញ ធនាគារ និងហិរញ្ញវត្ថុ គ្រប់គ្រង សេដ្ឋកិច្ច សវនកម្ម ឬជំនាញដែលពាក់ព័ន្ធ។
- មានបទពិសោធន៍ ០១(មួយ) ឆ្នាំក្នុងការធ្វើសវនករផ្ទៃក្នុង ទាក់ទងទៅនឹងវិស័យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។
- មានចំណេះដឹងទៅនឹងការរៀបចំផែនការហិរញ្ញវត្ថុ និងថវិកា គណនេយ្យទូទៅ សវនកម្មព័ត៌មានវិទ្យា ការគ្រប់គ្រងហានិភ័យ និងការត្រួត ពិនិត្យផ្ទៃក្នុង។
- មានចំណេះដឹងភាសាអង់គ្លេស៖ ស្តាប់ និយាយ អាន និងសរសេរ។
- មានចំណេះដឹងផ្នែកកុំព្យូទ័រ៖ Ms Office, Excel, Power point, E-mail ។ល។
- មានចំណេះដឹងការត្រួតពិនិត្យ និងជំនាញលើការគ្រប់គ្រងប្រតិបត្តិការធនាគារ/គ្រឹះស្ថានហិរញ្ញវត្ថុ។
- មានជំនាញក្នុងការប្រាស្រ័យទាក់ទងល្អ ធ្វើការជាក្រុម ឯករាជ្យភាព និងភាពជឿជាក់។
- មានសមត្ថភាពក្នុងការដោះស្រាយការងារច្រើន និងភាពមានស្មុគស្មាញ។
- មានសមត្ថភាពក្នុងការធ្វើការជាមួយអ្នកគ្រប់គ្រង និងក្រុមការងារ។
- មានសមត្ថភាពក្នុងការប្រើគំនិតច្នៃប្រឌិត កំណត់កិច្ចការអទិភាព និងអាចធ្វើការងារដែលរងសម្ពាធ ដើម្បីសម្រេចតាមផែនការ។
- ត្រូវមានសញ្ជាតិ ខ្មែរ និងមានប្រវត្តិរូបល្អ។

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
(៨៥៥) ២៣ ២២៤ ៣៣៣, ទូរសារ: (៨៥៥) ២៣ ២២២ ១៣១
info@futabamfi.com.kh www.futabamfi.com.kh Futaba Microfinance Plc.

| | |
|---|---|
| | - មានភាពស្មោះត្រង់ ការទទួលខុសត្រូវ ការប្តេជ្ញាចិត្ត ឯករាជ្យ និងមានភាពជឿជាក់ខ្ពស់។<br>- បង្ហាញក្រមសីលធម៌វិជ្ជាជីវៈល្អ។<br>- មានឆន្ទៈធ្វើដំណើរទៅខេត្ត។ |

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់ជូនបុគ្គលិកពេញសិទ្ធិនូវ អត្ថប្រយោជន៍ផ្សេងៗដូចជា៖

| | |
|---|---|
| ១. ផ្តល់ប្រាក់បៀវត្សប្រកួតប្រជែងទៅតាមបទពិសោធន៍។<br>២. ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ ១០០% នៃប្រាក់បៀវត្ស។<br>៣. ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ១០០% នៃប្រាក់បៀវត្ស។<br>៤. ការធានារ៉ាប់រងសុខភាពដល់បុគ្គលិក និងសមាជិកគ្រួសារ (ប្តី/ប្រពន្ធ និងកូន២នាក់)។<br>៥. ការធានារ៉ាប់រងគ្រោះថ្នាក់ដល់ជីវិត ២៤ ម៉ោង។<br>៦. ប្រាក់ឧបត្ថម្ភចំណងដៃ អាពាហ៍ពិពាហ៍បុគ្គលិក។<br>៧. ផ្តល់ប្រាក់កម្ចីដល់បុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ។<br>៨. ការឈប់សម្រាកអនុលោមតាមច្បាប់ក្រសួងការងារ និងការឈប់សម្រាកប្រចាំឆ្នាំ។ | ៩. ផ្តល់ឯកសណ្ឋានការងារ។<br>១០. ប្រាក់ឧបត្ថម្ភថ្លៃសាំង $៥០ក្នុង១ខែ។<br>១១. ប្រាក់ឧបត្ថម្ភ និងសម្ភារៈប្រើប្រាស់ផ្សេងៗតាមគោលការណ៍កំណត់របស់គ្រឹះស្ថាន **ហ្វូតាបា**។ |

- **របៀបដាក់ពាក្យ៖** បេក្ខជន / បេក្ខនារី ដែលមានចំណាប់អារម្មណ៍បំពេញការងារជាមួយ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមផ្ញើពាក្យសុំបម្រើការងារ (**CV និង Cover Letter**) ជាមួយរូបថត (**4x6**) ដោយបញ្ជាក់ពីមុខតំណែង និងទីតាំងដែលចង់បម្រើការងារឲ្យបានច្បាស់លាស់ និងយកមកដាក់នៅតាមការិយាល័យសាខារបស់ **ហ្វូតាបា** ឬអាចផ្ញើមកតាមរយៈ Email: recruitment@futabamfi.com.kh (នាយកដ្ឋានធនធានមនុស្ស)។
- សូមបញ្ជាក់ឲ្យបានច្បាស់លាស់អំពីប្រាក់បៀវត្សរំពឹងទុក។
- **ឈប់ទទួលពាក្យត្រឹម៖ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ ម៉ោង ០៥:០០ ល្ងាច** *(អ្នកដាក់ពាក្យមុនត្រូវបានលើកទឹកចិត្ត)*
- **សម្រាប់ព័ត៌មានបន្ថែម៖**

  សូមទំនាក់ទំនងផ្នែកធនធានមនុស្ស ទូរស័ព្ទលេខ: **070 479 333** ឬចូលទៅកាន់គេហទំព័រ: www.futabamfi.com.kh ឬ Facebook: Futaba Microfinance Plc.

*(បេក្ខជន ឬបេក្ខនារី ដែលបានដាក់ពាក្យរួចហើយមិនអាចដកពាក្យវិញបានឡើយ)*